ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពត៌មាន

លេខ ០០៣៧/៩៩ ព.ម.សរ.៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៩

## សារាចរណែនាំ

រយៈកាលកន្លងមក គ្រប់ស្ថានីយ៍វិទ្យុទូរទស្សន៍ និងទូរទស្សន៍ខ្សែកាបបានខិតខំអនុវត្តតាមការណែនាំជាបន្តបន្ទាប់របស់ក្រសួងពត៌មាន ពិសេសអនុវត្តតាមបទបញ្ជាណែនាំស្តីពីវិស័យសោតទស្សន៍ ដោយទទួលនូវលទ្ធផលល្អប្រសើរ ហើយមានស្មារតីទទួលខុសត្រូវជាប្រចាំនូវរាល់កម្មវិធី និងពេលម៉ោងផ្សាយ ។

ទន្ទឹមនេះដែរ ក្រសួងពត៌មានសង្កេតឃើញ នៅមានចំណុចអសកម្មសេសសល់ខ្លះៗ ដែលពុំទាន់អនុវត្តបាននៅឡើយ ។ ដូច្នេះ ដើម្បីអោយសមស្របទៅនឹង ការយកចិត្តទុកដាក់នៃសង្គម ការគោរពសិទ្ធមនុស្ស ការគោរពច្បាប់ និងសេរីភាពនៃការបញ្ចេញមតិ អោយកាន់តែសុក្រិត្យថែមទៀតនោះ ក្រសួងពត៌មានសូមធ្វើការណែនាំលើវិស័យការងារផ្សព្វផ្សាយដូចតទៅៈ

១-ស្ថានីយ៍វិទ្យុទាំងអស់ ត្រូវចាក់បទភ្លេងគោរពទង់ជាតិ ដោយបន្តផ្ទាល់ពីស្ថានីយ៍វិទ្យុជាតិអោយបានព្រមៗគ្នា នៅវេលាម៉ោង៧.០០ព្រឹក និងនៅវេលាម៉ោង១៧.០០ល្ងាច ដោយបន្លឺពាក្យ "សូមគោរពទង់ជាតិ" ។ ចំពោះស្ថានីយ៍ទូរទស្សន៍ទាំងអស់ ត្រូវចាក់បទភ្លេងគោរពទង់ជាតិ និងរូបភាពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាបក់រវិចៗ ដោយបន្តផ្ទាល់ពីស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា អោយបានព្រមៗគ្នានៅវេលាម៉ោង ១៧.០០ ល្ងាច ។

២- ស្ថានីយ៍ទូរទស្សន៍ទាំងអស់ ត្រូវផ្សាយពត៌មានអោយឯកភាពគ្នា នៅវេលាម៉ោង១៩.០០ល្ងាច ហើយប្រភពពត៌មានទាំងអស់ត្រូវឈរលើមូលដ្ឋាននៃការពិត មិនលំអៀង មិនរំលោភលើសេរីភាពរបស់បុគ្គលណាមួយឡើយ ។

រាល់ការផ្សព្វផ្សាយមិនអនុញ្ញាតអោយបកស្រាយ មិនត្រូវប៉ះពាល់ព្រះមហាក្សត្រ គោលនយោបាយរាជរដ្ឋាភិបាល សន្តិសុខសណ្តាប់ធ្នាប់សង្គម និងវប្បធម៌ប្រពៃណីខ្មែរ និងមិនផ្សាយអោយមានការប្រកាន់ពូជសាសន៍ និងប្រឆាំងជំនឿសាសនា ។មិនអនុញ្ញាតអោយផ្សាយពាណិជ្ជកម្ម ក្នុងចន្លោះម៉ោង ផ្សាយពត៌មានជាតិ និងអន្តរជាតិ ។